ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

សារលិខិតរំលែកមរណៈទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម ថោ សេដ្ឋាណា និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងខ្លាំងដោយបានទទួលដំណឹងថា ឧបាសិកា ឈន ម៉ាលី ដែលត្រូវជាម្តាយបង្កើត ឯកឧត្តម ថោ សេដ្ឋាណា រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈបានទទួលមរណភាពនៅថ្ងៃពុធ ១០កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៥:៤៥ នាទីព្រឹក ក្នុងជន្មាយុ ៨១ ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានចិត្តដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់សូមសម្តែងនូវមរណៈទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកកប្បការជូនចំពោះ ឧបាសិកា ឈន ម៉ាលី ដែលបានធ្វើមរណកាលលាចាកលោក លាចាកពីបុត្រធីតា និងក្រុមញាតិគ្រួសារជាទីស្រលាញ់។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសិកា ឈន ម៉ាលី បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម** និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុកដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ ពុធ ១០ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

ប្រាំ សុខា